ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ថ្ងៃ សុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃជាសាធារណៈនូវទំនិញគ្មានការទាមទារ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ពាណិជ្ជករដែលជាម្ចាស់ក្រុមហ៊ុន/សហគ្រាសបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា អគរ នឹងរៀបចំដាក់ឱ្យដេញថ្លៃជាសាធារណៈនូវទំនិញគ្មានការទាមទារ នូវស្រា ម៉ាក WHISKY និង BRANDY ចំនួន 1,517 កេស = 63,936 ដប ផ្ទុកក្នុងកុងតឺន័រចំនួន ០៤ ដូចខាងក្រោម÷

- SEGU3168091/20´ ស្រា Brandy ម៉ាក McDowells (48Bt x 180ml) 560 កេស = 26,880 ដប
- CCLU3944346/20´ ស្រា Brandy ម៉ាក McDowells (48Bt x 180ml) 217 កេស = 10,416 ដប
  និងស្រា Whisky ម៉ាក Signature Rare Aged (48Bt x 180ml) 190 កេស = 9,120 ដប
- FCIU4826650/20´ ស្រា Whisky ម៉ាក Signature Rare Aged (48Bt x 375ml) 370 កេស = 8,880 ដប
- BMOU2392094/20´ ស្រា Whisky ម៉ាក Signature Rare Aged (48Bt x 180ml) 180 កេស = 8,640 ដប

ក្នុងន័យនេះ អគរ សូមអញ្ជើញបណ្តាក្រុមហ៊ុន/សហគ្រាសដែលមានបំណងចង់ចូលរួមដេញថ្លៃ សូមអញ្ជើញមកទទួលនិងដាក់ពាក្យស្នើសុំនៅ នាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ (ជាន់ទី១៦) នៃ អគរ ដែលមានអាសយដ្ឋានលេខ ៦-៨ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី១៨ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ រៀងរាល់ម៉ោងធ្វើការ ។

ប្រសិនបើមានសំណួរ ឬតម្រូវការព័ត៌មាននានាទាក់ទងនឹងការដាក់ដេញថ្លៃនេះ សូមមេត្តាសាកសួរព័ត៌មានបន្ថែមតាមទូរស័ព្ទលេខ: ០៩២ ៨៥៥ ៩៩៩, ០១២ ៩១៨ ៩១៨។

អាស្រ័យហេតុនេះ សូមពាណិជ្ជករពាក់ព័ន្ធទាំងអស់ដែលមានបំណងចូលរួមដេញថ្លៃ សូមមេត្តាជ្រាបជាព័ត៌មាន ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា
អគ្គនាយក

ហេង-សំអូន

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៩៧ / E-mail: info-pru@customs.gov.kh